**ស្ថានទូតអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា** **ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

# សេចក្តីប្រកាសព័ត៌មានរួម

## ស្តីពីការប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តផែនការអភិវឌ្ឍន៍សម្រាប់ឆ្លើយតបនឹងជំងឺកូវីដ-១៩ នៅកម្ពុជា

នាថ្ងៃពុធ ៩រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០, អូស្ត្រាលី និងកម្ពុជា បានប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តផែនការអភិវឌ្ឍន៍សម្រាប់ឆ្លើយតបនឹងជំងឺកូវីដ-១៩ នៅកម្ពុជា (Cambodia COVID-19 Development Response Plan) ។ ក្នុងស្មារតីភាពជាដៃគូ រដ្ឋាភិបាលអូស្ត្រាលី ដោយសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈកិច្ចពិគ្រោះយោបល់ជាបន្តបន្ទាប់ បានរៀបចំផែនការនេះដែលមានសុពលភាពរហូតដល់ខែមិថុនា ឆ្នាំ២០២២ ដើម្បីតម្រង់ទិសការគាំទ្ររបស់អូស្ត្រាលី សម្រាប់ស្តារសេដ្ឋកិច្ច-សង្គមកម្ពុជា ពីវិបត្តិជំងឺកូវីដ-១៩ ។

ផែនការនេះបានកំណត់អំពីការគាំទ្ររបស់អូស្ត្រាលីសម្រាប់ការស្តារកម្ពុជា តាមរយៈសសរស្តម្ភ ៣ គឺ÷ ការធានាសន្តិសុខផ្នែកសុខាភិបាល, ស្ថិរភាពសង្គមនិងបរិយាប័ន្ន និងការស្តារសេដ្ឋកិច្ច ។

ឯកឧត្តម **ផាប្លូ កាង** ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា រដ្ឋាភិបាលអូស្ត្រាលីនឹងវិនិយោគលើចង្កោមសកម្មភាពនៃសសរស្តម្ភទាំង ៣ ដើម្បីស្តារសេដ្ឋកិច្ច និងសង្គមកម្ពុជា ពីវិបត្តិជំងឺកូវីដ-១៩ ។ ចង្កោមសកម្មភាពទាំងនោះរួមមាន÷ ការធ្វើឱ្យប្រសើរឡើងគុណភាព និងភាពងាយស្រួលក្នុងការទទួលបានសេវាសុខភាពតាមមន្ទីរពេទ្យ, ការលើកកម្ពស់យេនឌ័រ និងពិការភាព, ការជំរុញផលិតកម្មស្បៀង, ការគាំទ្រដល់ការផ្លាស់ប្តូរប្រភពថាមពល, និងការចូលរួមរបស់ប្រជាពលរដ្ឋជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីឆ្លើយតបនឹងជំងឺកូវីដ-១៩ ។

ដើម្បីអនុវត្តផែនការនេះ អូស្ត្រាលីគ្រោងផ្តល់ហិរញ្ញប្បទានឥតសំណងប្រមាណ ៨៥ លានដុល្លារអាមេរិក ដល់កម្ពុជា ដែលជាផ្នែកមួយនៃកម្មវិធីសហប្រតិបត្តិការទ្វេភាគីដែលកំពុងអនុវត្ត ។ ហិរញ្ញប្បទាននេះជាការផ្តល់បន្ថែមលើហិរញ្ញប្បទានប្រមាណ ១៧០ លានដុល្លារអាមេរិក ដែលឯកឧត្តម **Scott Morrison** នាយករដ្ឋមន្ត្រីអូស្ត្រាលី បានប្រកាសគាំទ្រដល់ការធ្វើសមាហរណកម្មសេដ្ឋកិច្ច និងការអភិវឌ្ឍរបស់បណ្តាប្រទេសក្នុងតំបន់ទន្លេមេគង្គ និងហិរញ្ញប្បទានប្រមាណ ៤៤៥ លានដុល្លារអាមេរិក ដែលអូស្ត្រាលីបានប្តេជ្ញាផ្តល់សម្រាប់ការចែកចាយវ៉ាក់សាំងជំងឺកូវីដ-១៩ ក្នុងតំបន់អាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិក ។

ឯកឧត្តម **ឈៀង យ៉ាណារ៉ា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងអគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា បានលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជាបានវាយតម្លៃខ្ពស់ចំពោះគោលដៅចម្បងនៃ

ផែនការនេះ ក្នុងការជួយការពារប្រជាជនកម្ពុជាដែលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ និងគាំទ្រការស្តារសេដ្ឋកិច្ចនិងសង្គមកម្ពុជា ឆ្ពោះទៅកាន់ឋានៈជាប្រទេសមានចំណូលមធ្យម ប្រកបដោយភាពធន់នឹងវិបត្តិ និងបរិយាប័ន្ន ។

ក្នុងពិធីនេះ ឯកឧត្តមរដ្ឋមន្ត្រី និងឯកឧត្តមឯកអគ្គរាជទូត បានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួម ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តផែនការអភិវឌ្ឍន៍សម្រាប់ឆ្លើយតបនឹងជំងឺកូវីដ-១៩ នៅកម្ពុជា ។

ឯកឧត្តម **ឈៀង យ៉ាណារ៉ា** បានបញ្ជាក់បន្ថែមថា អូស្ត្រាលីគឺជាដៃគូអភិវឌ្ឍន៍បុរេសកម្មមួយ ដែលបានចាត់វិធានការតាំងពីដើមដំបូង ក្នុងការរៀបចំផែនការអភិវឌ្ឍន៍សម្រាប់ឆ្លើយតបនឹងជំងឺកូវីដ-១៩ នេះ ។ ផែនការនេះបានបញ្ជាក់ពីកិច្ចសហការដ៏សំខាន់ក្នុងភាពជាដៃគូសម្រាប់ការអភិវឌ្ឍ រវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលអូស្ត្រាលី ។ រាជរដ្ឋាភិបាលកម្ពុជា បានវាយតម្លៃខ្ពស់ចំពោះផែនការនេះ ពិសេសសកម្មភាពអាទិភាព ដែលផ្តោតលើវិស័យសំខាន់ទាំង ៣ ដែលមានសង្គតិភាពជាមួយនឹងផែនការរបស់រាជរដ្ឋាភិបាល ក្នុងការស្តារសេដ្ឋកិច្ចនិងសង្គមកម្ពុជា ក្រោយវិបត្តិជំងឺកូវីដ-១៩ ។

ចុងបញ្ចប់ **ឯកឧត្តមឯកអគ្គរដ្ឋទូតអូស្ត្រាលី** បានមានប្រសាសន៍ថា អគារដ៏មានតេជរឹទ្ធិនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលយើងបានប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តផែនការនេះ គឺជាអតីតទីស្នាក់ការកណ្តាលរបស់អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា (UNTAC) ។ ដោយអូស្ត្រាលីបានបំពេញតួនាទីចម្បងក្នុងកិច្ចដំណើរការឆ្ពោះទៅរកសន្តិភាពនៅកម្ពុជា ហើយបច្ចុប្បន្នអូស្ត្រាលីកំពុងបន្តតួនាទីសំខាន់ក្នុងការផ្តល់ការគាំទ្រដល់កម្ពុជា សម្រាប់ស្តារសេដ្ឋកិច្ច និងសង្គម ដែលទទួលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ ។

ផែនការនេះមានក្នុងគេហទំព័រ÷ https://www.dfat.gov.au/sites/default/files/covid-response-plan-cambodia.pdf

ព័ត៌មានបន្ថែម: Australian.Embassy.Cambodia@dfat.gov.au